# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## លក្ខន្តិកៈ

## សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

Société Cambodgienne de Gynécologie et d'obstétrique

Cambodian Society of Gynecology and Obstetric

## ជំពូក១

## អំពីគោលបំណង និងគោលដៅ

ប្រការ១: គោលបំណង

សមាគមស.ស.ស.ក ប្រមូលផ្តុំគ្រូពេទ្យសម្ភព និងរោគស្ត្រី ក្នុងគោលបំណងរួមចំណែកលើកកម្ពស់គុណភាពសេវាកម្មបណ្តុះបណ្តាល និងស្រាវជ្រាវនៃមុខវិទ្យាសម្ភព និងរោគស្ត្រីវិទ្យា។

ប្រការ២: គោលដៅ

សមាគម ស.ស.ស.ក មានគោលដៅសំខាន់គឺ លើកកម្ពស់មនសិការជាតិ និងអន្តរជាតិព្រមទាំងប្រឆ្កើតស្មារតីទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការ និងការជឿនលឿននៃវិទ្យាសាស្ត្រ។ ក្នុងបំណងនេះហើយសមាគមត្រូវៈ

-ត្រិះរិះពិចារណាជានិច្ចកាលអំពីតួនាទី និងមុខតំណែងក្នុងសង្គមជាតិ និងអន្តរជាតិ ព្រមទាំងរចនាសម្ព័ន្ធ និងមធ្យោបាយរបស់ខ្លួន

-ជំរុញឲ្យមានសន្ទុះកាន់តែខ្លាំងរាល់សកម្មភាព ដែលបង្កឲ្យមានការជួបជុំគ្នាផ្នែកគរុកោសល្យ និងវិទ្យា សាស្ត្រ

-ផ្តល់ព័ត៌មានវិទ្យាសាស្ត្ររវាងគ្រូពេទ្យសម្ភព និងរោគស្ត្រីទាំងឡាយដែលជាសមាជិករបស់សមាគម

-អនុវត្តឲ្យបានសម្រេចនូវរាល់កម្មវិធីបណ្តុះបណ្តាល និងស្រាវជ្រាវវិទ្យាសាស្ត្រ ក្នុងអាណត្តិដែលកំណត់ ដោយសមាគម។

## ជំពូក ២

## អំពីឈ្មោះ អាសយដ្ឋាន អត្តសញ្ញាណ រូបសញ្ញា និងត្រា

ប្រការ៣: អំពីឈ្មោះ

សមាគមនេះមានឈ្មោះជាភាសាខ្មែរថា (សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា) សរសេរជាអក្សរកាត់ (ស.ស.ស.ក) សរសេរជាអក្សរអង់គ្លេសថា (Cambodian Society of Gynecology and Obstetric )និងភាសាបារាំង (Société Cambodgienne de Gynécologie et d'obstétrique ) សរសេរជាអក្សរកាត់ (S.C.G.O)។

ប្រការ៤ : អំពីអាសយដ្ឋាន

សមាគមមានទីស្នាក់ការកណ្ដាលស្ថិតនៅរាជធានីភ្នំពេញ។ សមាគមស.ស.ស.ក អាចមានទីស្នាក់ការ សាខា នៅតាមបណ្តារាជធានី ខេត្ត តាមតម្រូវការចាំបាច់របស់សមាគម។ ទីស្នាក់ការកណ្តាល ឬទីស្នាក់ការសាខា អាចផ្លាស់ប្តូរបានក្នុងករណីចាំបាច់ តាមការសម្រេចចិត្តដោយសំឡេងគាំទ្រ២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាល។

ប្រការ៥ : អត្តសញ្ញាណ

សមាគមស.ស.ស.ក គឺជាសមាគមមិនស្វែងរកប្រាក់កម្រៃជាឯកជន បង្កើននូវសុវត្ថិភាព ដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាពគ្រូពេទ្យផ្នែកសម្ភព និងរោគស្ត្រី ដោយធ្វើសកម្មភាពមិនប្រកាន់ពណ៌សម្បុរ ពូជសាសន៍ ជនជាតិសាសនា មិនធ្វើនយោបាយ មិនប្រកាន់និន្នាការនយោបាយ មិនផ្តល់ជាសម្ភារ ថវិកា ធនធាន មនុស្សដល់គណបក្សនយោបាយណាមួយឡើយ គឺបម្រើផលប្រយោជន៍សាធារណៈ និងសមាជិក។

ប្រការ៦: រូបសញ្ញា និងត្រា

ក-រូបសញ្ញា សមាគមភ្ជាប់នូវឧបសម្ព័ន្ធមួយដោយខ្សែក។

ខ- អំពីត្រា ដោយមានសណ្ឋានដូចទៅនឹងរូបសញ្ញាប្រើទឹកល័ក្តពណ៌ខៀវរាងមូលទំហំ៣៨មម។

## ជំពូក ៣
## អំពីសមាជិកភាព និងការបាត់បង់សមាជិកភាព

ប្រការ៧: សមាជិកនៃសមាគមមានចំនួន៣ប្រភេទ៖

-សមាជិកកិត្តិយស

-សមាជិកពេញសិទ្ធិ

-សមាជិកសហការ។

ប្រការ៨: សមាជិកកិត្តិយស

សមាជិកកិត្តិយសនៃសមាគមស.ស.ស.ក ត្រូវជ្រើសតាំងដោយសន្និបាត តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ដើម្បីត្រូវបានជ្រើសតាំងជាសមាជិកកិត្តិយសត្រូវ៖

-សមាជិកកិត្តិយសត្រូវបានផ្តល់ជូនចំពោះបេក្ខជន ដែលមានសមត្ថភាព និងបទពិសោធក្នុង ឬក្រៅ វិស័យវិជ្ជាជីវៈខាង សម្ភព និងរោគស្ត្រី

-សន្យាថា និងបង់ថ្លៃវិភាគទានប្រចាំឆ្នាំ

ប្រការ៩: សមាជិកពេញសិទ្ធិ

សមាជិពេញសិទ្ធិត្រូវជ្រើសតាំងដោយ សន្និបាត តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីបានពិនិត្យ នូវសំណុំបេក្ខភាព។

ដើម្បីត្រូវបានជ្រើសតាំងជាសមាជិកពេញសិទ្ធិត្រូវ៖

-ជាវេជ្ជបណ្ឌិត

-មានគុណសម្បត្តិគ្រប់គ្រាន់ បញ្ជាក់ដោយការផ្តល់សេវាផ្លូវការជាសាធារណៈ ឬឯកជនក្នុងការអនុវត្តវិជ្ជាជីវៈផ្នែក សម្ភព និងរោគស្ត្រីវិទ្យា ហើយបេក្ខជនត្រូវមានសញ្ជាតិខ្មែរ

-ដាក់បេក្ខភាពចំពោះប្រធានសមាគមស.ស.ស.ក

-ឧទ្ទេសនាមដោយសមាជិកពេញសិទ្ធិពីររូបនៃសមាគម

-សន្យាថា និងបង់វិភាគទានប្រចាំឆ្នាំ។

ប្រការ១០: សមាជិកសហការ

សមាជិសហការត្រូវជ្រើសតាំងដោយសន្និបាតតាមសំណូមពររបស់ក្រុមប្រឹក្សាភិបាល។

ដើម្បីត្រូវបានជ្រើសតាំងជាសមាជិកសហការត្រូវៈ

-កំពុងបំពេញការងារជាគ្រូពេទ្យផ្នែកសម្ភព រោគស្ត្រី ទោះបីបេក្ខជនមានសញ្ជាតិកម្ពុជា ឬសញ្ជាតិបរទេសក៏ដោយ

-ត្រូវឧទ្ទេសនាមដោយសមាជិកពេញសិទ្ធិពីររូបនៃសមាគម

-សន្យាថា និងបង់ថ្លៃវិទានប្រចាំឆ្នាំ។

អំពីវិភាគទានៈ

ក. សមាជិកពេញសិទ្ធិ និងកិត្តិយសនៃសមាគមត្រូវបង់វិភាគទានប្រចាំឆ្នាំដែលត្រូវកំណត់ដោយ សន្និបាតតាមសំណើរបស់ក្រុមប្រឹក្សាភិបាល។ សមាជិកសហការត្រូវបង់វិភាគទានស្មើនឹងពាក់កណ្តាលវិភាគទាននៃសមាជិកពេញសិទ្ធិ។

ខ. ពេលដែលសមាជិកណាម្នាក់មិនបានបង់វិភាគទានក្នុងរយៈពេលពីរឆ្នាំជាប់គ្នា សមាជិកនោះត្រូវចាត់ទុកថាបាត់សមាជិកភាពរបស់ខ្លួន ហើយនិងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសន្និបាតទេ។ ប៉ុន្តែក្នុងកាលៈទេសៈពិសេសក្រុមប្រឹក្សាភិបាលអាចព្យួរទុកសិននូវប្រការនេះដោយរង់ចាំការអនុម័តពីសន្និបាតក្នុងសម័យប្រជុំសាមញ្ញលើកក្រោយ។

ប្រការ១១: អំពីការបាត់បង់សមាជិកភាព និងការបដិសេធសមាជិកភាពៈ

-ជនដែលជាទណ្ឌិតតាមអំណាចសាលក្រមតុលាការ

-សមាជិកសកម្មដែលបង្ករហេតុចលាចលបណ្តាលឲ្យខូចប្រយោជន៍ដល់សមាគមដែលក្រុមប្រឹក្សាភិបាលសម្រេចបណ្តេញចេញ

-សមាជិកទាំងឡាយណាដែលធ្វើសកម្មភាពប្រាសចាកផ្ទុយទៅនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទបញ្ជានានារបស់សមាគម។

## ជំពូក៤

## អំពីរចនាសម្ព័ន្ធសមាគម តួនាទី ភារកិច្ច

ប្រការ១២: សមាគមស.ស.ស.ក មានរចនាសម្ព័ន្ធគ្រប់គ្រងដូចតទៅៈ

-សន្និបាត

-ក្រុមប្រឹក្សាភិបាល។

ប្រការ១៣: សន្និបាតគឺជាស្ថាប័នដឹកនាំកំពូលរបស់សមាគមស.ស.ស.ក សន្និបាតរបស់សមាគមនេះមានពីរប្រភេទគឺៈ សន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ។

ប្រការ១៤: សន្និបាតសាមញ្ញ គឺប្រារព្ធធ្វើឡើងជារៀងរាល់០១ឆ្នាំម្តងក្នុងគោលដៅសំខាន់ៗៈ

-បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាល

-ពិនិត្យវាយតម្លៃលើរបាយការណ៍ស្តីពីការងារដឹកនាំគ្រប់គ្រង និងរបាយការណ៍ហិរញ្ញវត្ថុក្នុងអាណត្តិកន្លងមក

-ពិនិត្យ និងអនុម័តទិសដៅសកម្មភាពរបស់សមាគមសម្រាប់អនុវត្តបន្ត

-ពិនិត្យនិងដោះស្រាយការងារផ្សេងៗទៀតដែលស្នើឡើងដោយក្រុមប្រឹក្សាភិបាល។

ប្រការ១៥: សន្និបាតវិសាមញ្ញ គឺប្រព្រឹត្តទៅយោងតាមការចាំបាច់របស់សមាគមដើម្បី ៖

-ពិនិត្យសម្រេចរបាយការណ៍ដឹកនាំគ្រប់គ្រងកន្លងមកបញ្ហាដែលកើតឡើងដោយពិសេសដែលត្រូវធ្វើការរៀបចំម្តងទៀត

-សម្រេចអំពីរបាយការណ៍ហិរញ្ញវត្ថុ ឬការងារសវនកម្មផ្ទៃក្នុង

-ពិនិត្យដោះស្រាយបញ្ហាផ្សេងៗដែលកើតមានក្នុងសមាគម។

ប្រការ១៦: លក្ខណៈគតិយុត្ត រាល់ការសម្រេចខាងលើរបស់សន្និបាតទាំងពីរប្រភេទមានតម្លៃគតិយុត្តបានលុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត៥០%+១លើកូរ៉ុមចូលរួមសន្និបាតយ៉ាងហោចណាស់២/៣នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាល។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងប្រធានសន្និបាតមានឧត្តមានុភាព។ ប្រធានសន្និបាត អាចជាប្រធានសមាគម ឬបុគ្គលដែលមានឯករាជ្យភាពតាមការជ្រើសរើសរបស់អង្គសន្និបាត។

ប្រការ១៧: កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំគ្នា០១ដងក្នុងមួយខែតាមការអញ្ជើញរបស់ប្រធានសមាគម និងអាចប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានសមាគម ឬ២/៣នៃសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យពិភាក្សាអនុម័តលើរបៀបវារៈដែលបានដាក់ជូនដោយប្រធានសមាគម ឬសមាជិកក្រុមប្រឹក្សា ភិបាល ក្នុងគោលបំណងដើម្បីរិះរកយុទ្ធវិធីអនុវត្តសកម្មភាពការងាររបស់សមាគមឲ្យមានភាពរីកចម្រើន។

ប្រការ១៨: ក្រុមប្រឹក្សាភិបាលមានសមាជិកយ៉ាងតិច០៣រូប និងមានអាណត្តិ០៥ឆ្នាំ។ នៅពេលបញ្ចប់អាណត្តិសមាជិកចាស់មានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជាថ្មីទៀតបាន។

ប្រការ១៩: សមាជិកក្រុមប្រឹក្សាភិបាលជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសំឡេងគាំទ្រ២/៣ នៃសមាជិកសកម្មរបស់សមាគមនិងមានសមាជិកយ៉ាងតិចចំនួន ០៣រូបដូចខាងក្រោម៖

| | |
|---|---|
| -ប្រធាន | ០១ រូប |
| -អនុប្រធាន | ០២ រូប |
| -អគ្គលេខាធិការ | ០១ រូប |
| -គណៈកម្មការវិទ្យាសាស្ត្រ | ០១ រូប |
| -គណៈកម្មការទំនាក់ទំនង | ០១រូប |
| -ហេរញ្ញិក | ០១រូប។ |

ប្រការ១២០: ប្រធានក្រុមប្រឹក្សាភិបាល

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធានសមាគម និងតំណាងស្របច្បាប់របស់សមាគមដែលមានតួនាទីទទួលបន្ទុកការងាររួម និងទទួលខុសត្រូវគ្រប់សកម្មភាពរបស់សមាគម។

ប្រការ២១: អំពីអនុប្រធាន

មានភារកិច្ចជួយកិច្ចការប្រធានសមាគមតាមការកំណត់របស់ប្រធាន និងមានតួនាទីជំនួសប្រធាននៅពេលប្រធានសមាគមអវត្តមានក្នុងឋានៈជាប្រធានស្តីទី ដោយមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធាន ។

ប្រការ២២: អគ្គលេខាធិការ

តួនាទី និងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងការងាររដ្ឋបាល ទ្រព្យសម្បត្តិ សារពើភណ្ឌ

-រៀបចំលិខិតបទដ្ឋាន និងរក្សាតម្កល់ទុកឯកសារ

-គ្រប់គ្រងការងារបុគ្គលិក

-ធ្វើកំណត់ហេតុក្នុងអង្គប្រជុំនានា និងអង្គសន្និបាត។

ប្រការ២៣: ហេរញ្ញិក

មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រងហិរញ្ញវត្ថុ និងត្រួតពិនិត្យរាល់ចំណូលចំណាយរបស់សមាគម។

-ធ្វើគម្រោងថវិកាប្រចាំឆ្នាំ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនប្រធានសមាគម និងដាក់ជូន ក្រុមប្រឹក្សាភិបាល និងសន្និបាតដើម្បីពិនិត្យសម្រេច។

ប្រការ២៤: គណៈកម្មការវិទ្យាសាស្ត្រ

មានតួនាទី និងភារកិច្ចស្រាវជ្រាវវិទ្យាដែលពាក់ព័ន្ធសម្ភព និងរោគស្ត្រីជូនប្រធានសមាគម និងដាក់ជូនក្រុមប្រឹក្សាភិបាល និងសន្និបាតដើម្បីពិនិត្យសម្រេច។

ប្រការ២៥: គណកម្មការទំនាក់ទំនង

មានតួនាទី និងភារកិច្ចទំនាក់ទំនងជាមួយបណ្តាលដៃគូរជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធសម្ភព និងរោគស្ត្រីជូនប្រធានសមាគម និងដាក់ជូនក្រុមប្រឹក្សាភិបាល និងសន្និបាតដើម្បីពិនិត្យសម្រេច។

## ជំពូក៥
## អំពីប្រភពមូលនិធិ និងការគ្រប់គ្រង

ប្រការ២៦: ប្រភពចំណូលរបស់សមាគមស.ស.ស.ក មាន៖

-ភាគទាន វិភាគទាន ឬវិបរិលទានរបស់សមាជិក

-អំណោយស្របច្បាប់គ្រប់ប្រភេទពីសំណាក់រូបវន្តបុគ្គល ឬនីតិបុគ្គលជាតិអន្តរជាតិ

-ចំណូលពីសកម្មភាពស្របច្បាប់នានារបស់សមាគម

-អំណោយពីរាជរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា

-អំណោយពីបណ្តាស្ថានទូតអន្តរជាតិ ឬភ្នាក់ងារផ្តល់ជំនួយនានា។

ប្រការ២៧: រាល់ចំណូលទាំងអស់របស់សមាគមស.ស.ស.ក ត្រូវគ្រប់គ្រងដោយហេរញ្ញិកសមាគមដោយ មានការចុះហត្ថលេខាយល់ព្រមពីប្រធានសមាគម។ ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រទាំងអស់ត្រូវបញ្ចូលទៅក្នុងគណនីធនាគារស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមសមាគម ស.ស.ស.ក តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ ថវិកាអាចរក្សាទុកមួយចំនួន ក្នុងបេឡារបស់សមាគមសម្រាប់ការប្រើប្រាស់ចាំបាច់របស់សមាគម តាមការកំណត់របស់ក្រុមប្រឹក្សាភិបាល។ រាល់ការដកសាច់ប្រាក់ ឬមូលប្បទានប័ត្រពីធនាគារត្រូវមានចុះហត្ថលេខារបស់ហេរញ្ញិក និងប្រធានសមាគម ឬអាចផ្ទេរសិទ្ធិទៅឱ្យរូបវន្តបុគ្គលដែលជាសមាជិកក្រុមប្រឹក្សាភិបាលដោយមាន ការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ។

## ជំពូក៦
## អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈនិងការរំលាយ

ប្រការ២៨: ការធ្វើវិសោធនកម្មលក្ខន្តិកៈបានដរាបណាមានការស្នើសុំពីប្រធានសមាគម ឬស្នើសុំដោយសំឡេង២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាល និងមានការសម្រេចពីសន្និបាតសាមញ្ញ ឬវិសាមញ្ញដោយសំឡេងភាគច្រើនដាច់ខាត។

ប្រការ២៩: អង្គសន្និបាតអាចសម្រេចរំលាយសមាគមស.ស.ស.ក នេះបាន។ នៅពេលសមាគមស.ស.ស.ក ត្រូវបានរំលាយសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មាការមួយដើម្បីជម្រះបញ្ជីសមាគម។ រាល់ទ្រព្យរបស់សមាគមដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់សមាគមរួចត្រូវផ្ទេរ ឬប្រគល់ជូនទៅអង្គការ ឬសមាគមស្របច្បាប់ណាដែលមាន គោលបំណងដូចសមាគមនេះ ឬប្រគល់ជូនសមាគមជាតិ កាកបាទក្រហមកម្ពុជា។ សមាជិកនិងបុគ្គលិកសមាគមទាំងអស់ក៏ត្រូវរំសាយផងដែរនៅពេល សមាគមត្រូវបានរំលាយ។

## ជំពូក៧
## អវសានប្បញ្ញត្តិ

ប្រការ៣០: រាល់បទប្បញ្ញត្តិទាំងឡាយណារបស់សមាគមស.ស.ស.ក ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះត្រូវទុកជានិរាករណ៍។

ប្រការ៣១: បន្ទាប់ពីសមាគមទទួលបានការចុះបញ្ជីនៅក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តសកម្មភាពសមាគមឲ្យត្រឹមត្រូវស្របតាមលក្ខន្តិកៈនេះ។ ក្នុងករណីបានប្រព្រឹត្តផ្ទុយពីលក្ខន្តិកៈនេះ អាជ្ញាធរមាន សមត្ថកិច្ចមានសិទ្ធិចាត់វិធានការតាមនីតិវិធីច្បាប់។

ប្រការ៣២: លក្ខន្តិកៈរបស់សមាគមស.ស.ស.ក មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥

**ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**គុំ ភាណរាល់**

**បានតម្កល់ទុកលក្ខន្តិកៈ**

[illegible]

នៅក្រសួងមហាផ្ទៃ តាមលិខិតលេខ: [illegible]

ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៥ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៥

**នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ**

**ប្រធាន**

ឈឹម ភាន

# រចនាសម្ព័ន្ធ

## សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

Société Cambodgienne de Gynécologie et d'obstétrique

**Cambodian Society of Gynecology and Obstetric**

**សន្និបាត**

↓

**ក្រុមប្រឹក្សាភិបាល**
**ប្រធាន**
លោក គុំ កាណាល់

↓

**អនុប្រធាន**
លោកស្រី គ្រុយ លាងស៊ីម
លោកស្រី ទុង វដ្ឋារី

↓

**អគ្គលេខាធិការ**
លោក សៀង ថារិទ្ធ

↓

| **គណៈកម្មការវិទ្យាសាស្ត្រ** | **គណៈកម្មការទំនាក់ទំនង** | **ហេរញ្ញិក** |
|---|---|---|
| **ប្រធាន** | **ប្រធាន** | លោកស្រី គាំ ផល្លី |
| លោក សាន់ ច័ន្ទសឿន | លោក ប៊ុច សុធី | |

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៥

**ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**គុំ កាណាល់**

SCGO

# ឧបសម្ព័ន្ធ

## រូបសញ្ញាសមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា

SOCGO